# Statewide Specialist Clinical Consultation Service

*A service provided by the Queensland Transcultural Mental Health Centre*

## សេវាកម្មពិគ្រោះយោបល់ព្យាបាលសំរាប់វប្បធម៌ទាំងឡាយ (KHMER)

### *តើ Transcultural Clinical Consultation Service គឺជាអ្វីទៅ ?*

នេះគឺជាសេវាកម្មឯកទេសខាងសុខភាពផ្លូវចិត្តទូទាំងរដ្ឋ ដែលផ្តល់ដោយ Qld Transcultural Mental Health Centre សំរាប់អ្នកមកពីសាវតារមិននិយាយអង់គ្លេស។ សេវាកម្មនេះ ឥតគិតថ្លៃទេ។

### *តើនរណាទៅដែលអាចប្រើ Transcultural Clinical Consultation Service?*

បើលោកអ្នកមានការបារម្ភអំពីបញ្ហាសុខភាពផ្លូវចិត្តសំរាប់ខ្លួនលោកអ្នកផ្ទាល់, សមាជិកគ្រួសារ ឬ មិត្តភក្តិ លោកអ្នកអាចទាក់ទងមណ្ឌលនេះ។

### *តើសេវាកម្មនេះអាចជួយតាមវិធីណាទៅ?*

Transcultural Clinical Consultation Service អាចផ្តល់ពត៌មាននិងឱវាទអំពីបញ្ហាសុខភាពផ្លូវចិត្តដែលលោកអ្នកមានការបារម្ភ ហើយតភ្ជាប់លោកអ្នកទៅនឹងសេវាកម្មទាំងពួងដែលអាចជួយលោកអ្នកបាន។ បើត្រូវការជំនួយថែមទៀត យើងអាចផ្តល់ជំនួយរយៈពេលខ្លីជូនលោកអ្នក ដើម្បីទៅជួបបុះដោះស្រាយជាមួយសេវាកម្មសុខភាពផ្លូវចិត្តមួយ ដោយមានជំនួយពីបុគ្គលិកសុខភាពផ្លូវចិត្តមួយរូបមកពីសាវតារវប្បធម៌និងភាសារបស់លោកអ្នកផ្ទាល់។

បុគ្គលិកសុខភាពផ្លូវចិត្ត អាចជួយលោកអ្នក ដោយ:

- ពន្យល់បញ្ហាវប្បធម៌ទៅកាន់សេវាកម្មសុខភាពផ្លូវចិត្តនោះ
- ជួយលោកអ្នកក្នុងការផ្តល់មតិលើផែនការព្យាបាលនិងថែទាំលោកអ្នក
- ជួបលោកអ្នកដើម្បីពិភាក្សាបញ្ហាសុខភាពផ្លូវចិត្តរបស់លោកអ្នក ជាភាសារបស់លោកអ្នកផ្ទាល់
- ពន្យល់បញ្ហាសុខភាពផ្លូវចិត្តរបស់លោកអ្នក ទៅកាន់សមាជិកទាំងពួងរបស់គ្រួសារលោកអ្នក
- ផ្តល់ជំនួយរយៈពេលខ្លី ដូចជាការគាំទ្រឬការពិគ្រោះឱវាទដែលទាក់ទិននឹងបញ្ហាសុខភាពផ្លូវចិត្ត។

### *តើជំនួយអ្វីទៀតទៅដែលគេអាចផ្តល់ឲ្យនោះ?*

មណ្ឌលនេះក៏មានពត៌មានជាលាយលក្ខណ៍អក្សរអំពីរោគផ្លូវចិត្តនិងពត៌មានដែលទាក់ទិន ជាភាសាចំបងភាគច្រើនផងដែរ។ បើលោកអ្នកគ្រាន់តែមានបំណងពិភាក្សាបញ្ហាណាមួយដែលទាក់ទិននឹងសុខភាពផ្លូវចិត្តលោកអ្នក ដូចជាអាការរោគ, ការព្យាបាល, ថ្នាំពេទ្យ និងពត៌មានអំពីសេវាកម្មសុខភាពផ្លូវចិត្តក្នុងតំបន់ លោកអ្នកក៏អាចទូរស័ព្ទទៅកាន់មណ្ឌលនេះផងដែរ។

### *តើសេវាកម្មនេះលាក់ការណ៍សម្ងាត់ឬទេ?*

ហ្នឹងហើយ ដូចគ្នានឹងអ្នកវិជ្ជាជីវៈសុខភាពឯទៀតទាំងអស់ដែរនោះ បុគ្គលិកសុខភាពផ្លូវចិត្តរបស់យើងត្រូវគោរពទៅតាមបទបញ្ញត្តិតឹងរ៉ឹងក្នុងការលាក់ការណ៍សម្ងាត់ ហើយគ្មានការអនុញ្ញាតដើម្បីពិភាក្សាបញ្ហារបស់លោកអ្នកជាមួយអ្នកដទៃដោយគ្មានការអនុញ្ញាតដោយផ្ទាល់របស់លោកអ្នកឡើយ។

### *តើខ្ញុំគួររំពឹងអ្វីទៅនៅពេលខ្ញុំទទួលសេវាកម្មពី Transcultural Clinical Consultation Service?*

លោកអ្នកអាចរំពឹងទទួលការព្យាបាលប្រកបដោយការគោរព, កិត្តិយស និងការពិចារណាលើភាពផ្ទាល់ខ្លួន, សាសនា និងសាវតារវប្បធម៌របស់លោកអ្នក។

គេនឹងសុំការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីលោកអ្នក មុនពេលទាក់ទងនឹងបុគ្គលិកសុខភាពផ្លូវចិត្តមកពីសាវតារវប្បធម៌ ឬភាសារបស់លោកអ្នក។

### *តើខ្ញុំទាក់ទងសេវាកម្មនេះតាមរបៀបណា?*

បើលោកអ្នកនៅក្នុង Brisbane លោកអ្នកអាចទូរស័ព្ទទៅលេខ (07) 3167-8333 ហើយបើលោកអ្នកនៅក្រៅ Brisbane សូមទូរស័ព្ទទៅលេខ 1800 188-189 ថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ម៉ោង 8.30 ព្រឹក – 4.30 ល្ងាច ហើយសុំជួបនិយាយជាមួយអ្នកសំរបសំរួលសេវាកម្មព្យាបាល។

### *ខ្ញុំមិនអាចនិយាយអង់គ្លេសបានទេ តើខ្ញុំអាចទូរស័ព្ទទៅកាន់សេវាកម្មនេះតាមវិធីយ៉ាងណា?*

លោកអ្នកអាចទូរស័ព្ទទៅសេវាកម្មបកប្រែភាសា តាមលេខ 131450 ដើម្បីសុំអ្នកបកប្រែភាសាលោកអ្នកម្នាក់ ហើយសុំឲ្យភ្ជាប់ទៅនឹង Qld Transcultural Mental Health Centre តាមទូរស័ព្ទលេខ (07) 3167-8333 ។ បន្ទាប់មក ការសារសងគ្នាដោយមនុស្សបីនាក់ អាចកើតមានឡើង។

**Queensland Transcultural Mental Health Centre**
**516 Kessels Road, Macgregor Q 4109**
**PO Box 6623, Upper Mt Gravatt Q 4122**

**ទូរស័ព្ទ (07) 3167-8333**
**ទូរសារ (07) 3167-8322**
**ទូរស័ព្ទដោយឥតគិតថ្លៃ: 1800 188 189**
**(នៅខាងក្រៅតំបន់ទីក្រុង)**
**អ៊ីមែល: tccs@health.qld.gov.au**

**ពេលម៉ោងធ្វើការ: ថ្ងៃច័ន្ទ – ថ្ងៃសុក្រ**
**8.30 ព្រឹក - 5.00 ល្ងាច**